ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ៥១០ ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ
- យោងតាមតម្រូវការចាំបាច់

### សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដែលមានសមាសភាពដូចខាងក្រោម៖



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អ៊ិត សំហេង** | រដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ពេជ សោភ័ន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម | **អ៊ុំ មាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម | **ហ៊ុយ ហានសុង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥- ឯកឧត្តម | **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធានប្រចាំការ |
| ៦- ឯកឧត្តម | **សាត សមុទ្រ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧- ឯកឧត្តម | **ហ៊ី ឌុឡារី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨- ឯកឧត្តម | **ឡេង សែ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩- ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១០- ឯកឧត្តម | **សេង សក្ដា** | អគ្គនាយកការងារ | សមាជិក |
| ១១- ឯកឧត្តម | **ឡៅ ហ៊ឹម** | អគ្គនាយក TVET | សមាជិក |
| ១២- ឯកឧត្តម | **ហុង ជឿន** | ប្រធាន ទ.ជ.ម.ក | សមាជិក |
| ១៣- ឯកឧត្តម | **ទេស រុក្ខាផល** | អគ្គលេខាធិការរង នៃ អ.គ.ក.ប | សមាជិក |
| ១៤- ឯកឧត្តម | **សោម ចំណាន** | ទីប្រឹក្សាអមក្រសួង | សមាជិក |

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ចៈ

- ដឹកនាំ និង គ្រប់គ្រងការកសាងនិងការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ
- សិក្សា កែសម្រួល និងរៀបចំតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យការងារ
- ចូលរួមផ្ដល់យោបល់ និង ត្រួតពិនិត្យលើខ្លឹមសារនិងទម្រង់នៃសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ជាមួយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌នៃក្រសួងយុត្តិធម៌
- ធ្វើការបកស្រាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ
- កំណត់កម្មវិធីកិច្ចប្រជុំរបស់គណៈកម្មការ ដើម្បីដាក់ផែនការការងារនិងពិនិត្យវឌ្ឍនភាពការងារ
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ក្នុងការសិក្សាស្រាវជ្រាវនិងលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ
- អនុវត្តតួនាទីនិងភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ២ .-**

ត្រូវបានបង្កើតលេខាធិការដ្ឋានមួយ ជាជំនួយការដល់គណៈកម្មការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម | **សោម ចំណាន** | ទីប្រឹក្សាអមក្រសួង | អនុប្រធាន |
| ៣- លោក | **អ៊ិន ខេមរា** | អគ្គនាយករងការងារ | អនុប្រធាន |
| ៤- កញ្ញា | **សុវណ្ណា វណ្ណារតន៍** | ទីប្រឹក្សាអមក្រសួង | សមាជិកា |
| ៥- លោក | **ហួន សុខនានាថ** | ទីប្រឹក្សាអមក្រសួង | សមាជិក |

| | | | | |
|---|---|---|---|---|
| ៦- | លោក | **ហៃ ហ៊ុនឡេង** | អនុប្រធាន ទ.ជ.ម.ក | សមាជិក |
| ៧- | កញ្ញា | **ស្រេង សុភាសរីវឌ្ឍនី** | ទីប្រឹក្សា ទ.ជ.ម.ក | សមាជិកា |
| ៨- | លោក | **ភុយ ទេពដារាវុធ** | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ៩- | លោក | **អ៊ុក ចាន់ធូ** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១០- | លោក | **ឌី ស៊ីម៉ាណែត** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិនិងនីតិកម្ម | សមាជិក |
| ១១- | លោក | **ឡេង តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១២- | លោក | **ម៉េង ហៀង** | ប្រធាននាយកដ្ឋានការងារកុមារ | សមាជិក |
| ១៣- | លោក | **ហ៊ីង ស៊ីដេត** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិក |
| ១៤- | លោក | **ថូ ម៉ិនថន** | អនុប្រធាន ន. មុខរបរ និងហាត្ថពលកម្ម | សមាជិក |
| ១៥- | លោក | **ហួន សឿរ** | អនុប្រធាន ន. វិវាទការងារ | សមាជិក |
| ១៦- | លោក | **ឯម សោភ័ណរិទ្ធ** | អនុប្រធាន ន. ការងារកុមារ | សមាជិក |
| ១៧- | លោក | **សោម វាសនា** | អនុប្រធាន ន. រដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៨- | លោក | **ជាវ ម៉ុនរិទ្ធ** | ប្រធាន ការិ. នៃ ប.ស.ស | សមាជិក |
| ១៩- | លោក | **អ៊ុក វ៉ាវុធ** | ប្រធាន ការិ. ត្រួតពិនិត្យពលករខ្មែរ | សមាជិក |
| ២០- | លោក | **ប៉ែន យ៉ារីម** | ប្រធាន ការិ. នីតិកម្ម | សមាជិក |
| ២១- | លោក | **គយចៅ វិសាល** | មន្ត្រី ន. មុខរបរ និងហាត្ថពលកម្ម | សមាជិក |
| ២២- | លោក | **ហាក់ ភក្តដារាស្សី** | មន្ត្រីខុទ្ទកាល័យ | សមាជិក |

លេខាធិការដ្ឋានមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារ និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងការកសាង និង ការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ
- រៀបចំសេចក្តីព្រាងដំបូងនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារជូនគណៈកម្មការ
- ផ្តល់សេវារដ្ឋបាលដល់គណៈកម្មការ
- រៀបចំផែនការថវិកាសម្រាប់អនុវត្តការងារ
- រៀបចំកិច្ចប្រជុំនានារបស់គណៈកម្មការ ក៏ដូចជា កិច្ចប្រជុំទ្វេភាគី កិច្ចប្រជុំត្រីភាគី កិច្ចប្រជុំអន្តរក្រសួង និងសិក្ខាសាលាពិគ្រោះយោបល់របស់គណៈកម្មការ និងក្រុមការងារបច្ចេកទេស
- ធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំ សិក្ខាសាលារបស់គណៈកម្មការ រៀបចំរបាយការណ៍លទ្ធផលការងាររបស់ក្រុមការងារបច្ចេកទេសជូនគណៈកម្មការ
- អនុវត្តតួនាទី និងភារកិច្ចផ្សេងៗទៀតដែលគណៈកម្មការប្រគល់ជូន។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។



ឦ

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកការងារ អគ្គនាយកអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ នាយកបេឡាជាតិរបបសន្តិសុខសង្គម គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ ១-២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ